ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៣៩០០......អពដ

ថ្ងៃ សុក្រ ០៧កើត ខែ ចេត្រ ឆ្នាំខ្លូវ ត្រីស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ មេសា ឆ្នាំ២០២២

# សេចក្តីណែនាំ
## ស្តីពី
## ការដាក់ឱ្យអនុវត្តការដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing)

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ឱ្យបានជ្រាបថា អនុវត្តតាមសេចក្តីណែនាំលេខ ២០៥២២ អពដ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេសការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំដាក់បញ្ចូលមុខងារប្រកាសអាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing) ដើម្បីសម្រួលដល់ការដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែម (តាមវិធីគិតអាករជំនួស) ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ធានាបាននូវតម្លាភាព ភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលា និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ។

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនថា អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពីអ្នកជាប់ពន្ធអនិវាសនជន ត្រូវដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) សម្រាប់រយៈពេលជាប់ពន្ធខែមេសា ឆ្នាំ២០២២ តរៀងទៅ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសបង់ពន្ធអាជីវកម្មអនឡាញ (E-Filing) និងត្រូវអនុវត្តតាមបែបបទនិងនីតិវិធីដូចខាងក្រោម÷

### I. សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ

អ្នកជាប់ពន្ធមធ្យមនិងធំទាំងអស់ត្រូវដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសបង់ពន្ធអាជីវកម្មអនឡាញ (E-Filing) យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងអាករនោះបានកើតឡើង ដោយរួចផុតពីពន្ធបន្ថែម ១០% ពីការយឺតយាវក្នុងការដាក់លិខិតប្រកាស។ ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filling) សម្រាប់អ្នកជាប់ពន្ធមធ្យម និងធំត្រូវអនុវត្តដូចខាងក្រោម÷

### ១. ការប្រើប្រាស់ប្រព័ន្ធ

ចំពោះការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសបង់ពន្ធអាជីវកម្មអនឡាញ (E-Filing) របស់អគ្គនាយកដ្ឋានពន្ធដារ អ្នកប្រើប្រាស់ដែលពុំទាន់បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធដោយចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ដើម្បីចុះបញ្ជីប្រើប្រាស់ប្រព័ន្ធ ដោយត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម÷



អគារកែងមហាវិថី សហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

- លេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT TIN)
- លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណប្លាស្ទិកដែលអគ្គនាយកដ្ឋានពន្ធដារផ្តល់ជូនលោក-លោកស្រី
- លេខទូរស័ព្ទដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនឹងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

អ្នកប្រើប្រាស់នឹងទទួលបាន ឈ្មោះអ្នកប្រើប្រាស់ (User Name) និងលេខកូដសម្ងាត់ (Password) ដែលត្រូវបានផ្ញើទៅកាន់អ៊ីម៉ែល (E-mail) និងលេខទូរស័ព្ទរបស់ម្ចាស់សហគ្រាសឬអ្នកប្រើប្រាស់ នៅពេលព័ត៌មានដែលតម្រូវខាងលើត្រូវបានវាយបញ្ចូលពេញលេញ។

**២. នីតិវិធីលម្អិតក្នុងការប្រើប្រាស់ប្រព័ន្ធសម្រាប់ដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស)**

ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing) អ្នកប្រើប្រាស់ត្រូវអនុវត្តនីតិវិធីលម្អិត ដូចខាងក្រោម÷

- ចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ដោយប្រើប្រាស់គណនីប្រើប្រាស់ប្រព័ន្ធ និងជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ
- ស្វែងរកព័ត៌មានសហគ្រាសធ្វើការប្រកាសពន្ធ
- ជ្រើសរើសមីនុយបញ្ចូលព័ត៌មានប្រកាសពន្ធ
- បញ្ចូលបញ្ជីទំនិញ ឬសេវានីជីថល (វិធីគិតអាករជំនួស)
- បំពេញព័ត៌មានទំនិញ ឬសេវានីជីថល÷
  1. ជ្រើសរើសកាលបរិច្ឆេទ
  2. ជ្រើសរើសអ្នកផ្គត់ផ្គង់អនិវាសនជន
  3. លេខអត្តសញ្ញាណកម្មសារពើពន្ធសាមញ្ញ (ឈ្មោះសហគ្រាស/ ប្រទេស/ សារអេឡិចត្រូនិក)
  4. លេខវិក្កយបត្រ
  5. ជ្រើសរើសប្រភេទផ្គត់ផ្គង់ទំនិញនិងសេវានីជីថល
  6. តម្លៃមិនរួមអាករ
  7. បរិយាយ
- ជ្រើសរើសមីនុយប្រកាសពន្ធប្រចាំខែ
- ជ្រើសរើសការប្រកាសអាករលើតម្លៃបន្ថែម (បង់តាមវិធីគិតអាករជំនួស)
- ពិនិត្យតារាងអាករលើតម្លៃបន្ថែមត្រូវបង់
- ជ្រើសរើសបញ្ជីអាករលើតម្លៃបន្ថែម (បង់តាមវិធីគិតអាករជំនួស)
- បោះពុម្ពពាក្យស្នើសុំបង់និងប្រកាសអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (បង់តាមវិធីគិតអាករជំនួស)
- ក្នុងការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធអាចបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) ក្នុងករណីនេះអ្នកជាប់ពន្ធពុំចាំបាច់យកលិខិតប្រកាសមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ។ ដោយឡែកក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារដៃគូដែល

បានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ្នកជាប់ពន្ធត្រូវយកបង្កាន់ដៃទទួលប្រាក់ពន្ធមកកាន់រដ្ឋបាលសារពើពន្ធដែលគ្រប់គ្រងសហគ្រាសនោះ

- ជ្រើសរើសមិនុយបញ្ចូលព័ត៌មានប្រកាសពន្ធ
- បញ្ចូលបញ្ជីទិនិញ ឬសេវាឌីជីថល (វិធីគិតអាករជំនួស)
- ជ្រើសរើសប៊ូតុងស្នើសុំឥណទានអាករលើធាតុចូល (ករណីនេះ អ្នកជាប់ពន្ធត្រូវធ្វើការបង់ប្រាក់អាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) ជាមុនសិនទើបអាចធ្វើការស្នើសុំឥណទានបាន។

*ដើម្បីធ្វើការស្វែងយល់បន្ថែមអំពីការប្រើប្រាស់មុខងារ បញ្ជីទិញទំនិញ ឬសេវាឌីជីថល (វិធីគិតអាករជំនួស) ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing) អ្នកប្រើប្រាស់អាចពិនិត្យមើលលម្អិតក្នុងសៀវភៅណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing) របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាននៅក្នុងគេហទំព័រ https://tax.gov.kh ឬចូលទស្សនាវីដេអូណែនាំ (Video Tutorial) ឬអាចទូរស័ព្ទមក Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។*

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីជាអភិបាលបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំស្តីពីការដាក់ឱ្យអនុវត្តការដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing) ដើម្បីធ្វើការដាក់លិខិតប្រកាស និងបង់ប្រាក់អាករលើតម្លៃបន្ថែមប្រចាំខែតាមវិធីគិតអាករជំនួស ឱ្យបានត្រឹមត្រូវ និងទទួលបានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**